# សន្និសីទជាតិ
# ស្ដីពី
# កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖ “ មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត ”

ថ្ងៃ៧-៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៨
រាជធានីភ្នំពេញ មជ្ឈមណ្ឌលសន្និបាតកោះពេជ្រ

## សុន្ទរកថាបើក
## សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- **ឯកឧត្ដមទេសរដ្ឋមន្ត្រី ឯកឧត្ដម លោកជំទាវរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ**
- **ឯកឧត្ដមប្រធានក្រុមប្រឹក្សា ឯកឧត្ដមអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានមន្ទីរជំនាញពាក់ព័ន្ធនានា**
- **លោក លោកស្រីប្រធានក្រុមប្រឹក្សា អភិបាលក្រុង ស្រុក មេឃុំ ចៅសង្កាត់**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា**
- **លោក លោកស្រី សមាជិក សមាជិកានៃសន្និសីទជាតិ ជាទីមេត្រី**!

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាម គ.ជ.អ.ប ខ្ញុំសូមសំដែងនូវការស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា តំណាងអគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដែលបានអញ្ជើញចូលរួមក្នុងសន្និសីទជាតិស្ដីពី " **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖ មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត** "ក្នុងឱកាសដ៏មហានក្ខត្តឫក្ស អធិកអធមនេះ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាមគ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីនៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍នានា អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមដឹកនាំ អនុវត្ត និងផ្ដល់ការគាំទ្រយ៉ាងសកម្ម

ដល់កិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងរយៈពេលជិត២ទសវត្សរ៍កន្លងមក ដោយបានជំរុញឱ្យកំណែទម្រង់នេះមានការវិវឌ្ឍទៅមុខជាជំហានៗ ស្របតាមដំណាក់កាលនីមួយៗដែលបានកំណត់ក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ដំណាក់កាលទី២ និងដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រោមប្រធានបទ " មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត" ដែលបានរៀបចំនាពេលនេះជាឱកាសមួយដ៏សមស្រប ដោយសារកំណែទម្រង់នេះបានឈានចូលដំណាក់កាលកាន់តែស៊ីជម្រៅ និងសាំញ៉ាំទាំងនៅក្នុងកិច្ចការនយោបាយ និងបច្ចេកទេសក្នុងក្របខ័ណ្ឌនៃការបែងចែកមុខងារ និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងរដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយថ្នាក់ជាតិ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព កាន់តែមានការឆ្លើយតបប្រកបដោយតម្លាភាព គណនេយ្យភាព និងសមធម៌សង្គម។

លើមូលដ្ឋាននេះ សន្និសីទជាតិនាឱកាសនេះមានគោលបំណងសំខាន់ចំនួន៣គឺ៖

**ទីមួយ៖** ការផ្សព្វផ្សាយ និងណែនាំអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨របស់ គ.ជ.អ.ប. ដែលជាការចាប់ផ្តើមអនុវត្តផែនការអនុវត្ត៣ឆ្នាំដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ទីពីរ៖** ការរួមគ្នាពិនិត្យមើលឡើងវិញនូវសមិទ្ធផល មេរៀនបទពិសោធន៍ ដែលយើងទទួលបានក្នុងកិច្ចដំណើរការកំណែទម្រង់រយៈពេលជិត២ទសវត្សរ៍កន្លងមកនេះ ព្រមទាំងពិនិត្យ និងវាយតម្លៃបញ្ហាប្រឈមដែលនៅសេសសល់ និងការពិភាក្សាកំណត់អំពីដំណោះស្រាយបញ្ហាប្រឈមទាំងនោះ សំដៅរួមគ្នាជំរុញកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះឱ្យបោះជំហានទៅមុខជាបន្តទៀត។

**ទីបី៖** ការរួមគ្នាកំណត់អំពីចក្ខុវិស័យនៃកំណែទម្រង់នេះក្នុងដំណាក់កាលនៃការអនុវត្តផែនការចុងក្រោយនៃកម្មវិធីជាតិ សំដៅពង្រឹងការប្តេជ្ញាចិត្តខាងនយោបាយក្នុងការឆ្ពោះទៅសម្រេចបាននូវលទ្ធផលរពឹងទុកចម្បងៗ ក្នុងសមាសធាតុនានានៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ពាក់ព័ន្ធនឹងការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨នេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានខិតខំសម្របសម្រួល ពិភាក្សា ពិគ្រោះយោបល់ជាច្រើនលើកជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា។ ការរៀបចំ និងការអនុវត្ត

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨នេះមានភាពខុសគ្នាជាមួយនឹងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំមុនៗ ដែលតម្រូវឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិព្រងឹងភាពជាម្ចាស់ក្នុងការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយប្រើប្រាស់ថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ ជំនួសឱ្យថវិកាដែលធ្លាប់បានទទួលពី គ.ជ.អ.ប.។ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តខិតខំពង្រឹងសមត្ថភាពស្ថាប័ន និងយន្តការនានារបស់ខ្លួន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។ ទន្ទឹមគ្នានេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើសេចក្តីរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការ ប្រចាំឆ្នាំនេះមក គ.ជ.អ.ប. ដើម្បីពិនិត្យដោះស្រាយ និងរាយការណ៍ជូនរាជរដ្ឋាភិបាល។ គ.ជ.អ.ប. នឹងបន្តខិតខំកៀរគរ និងស្វាគមន៍ចំពោះដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ក្នុងការចូលរួមគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ការអនុវត្តកម្មវិធីកំណែទម្រង់នេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** !

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅថាកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់ដែលមានការពាក់ព័ន្ធទៅគ្រប់វិស័យ គ្រប់ស្ថាប័ន និងគ្រប់ការដ្ឋានកំណែទម្រង់នានា ដែលចាំបាច់ទាមទារឱ្យមានការចូលរួមចំណែកយ៉ាងសកម្មពីគ្រប់វិស័យ គ្រប់ស្ថាប័ន និងគ្រប់ការដ្ឋានកំណែទម្រង់ទាំងនោះដោយផ្តោតលើអភិក្រម **រួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ**។ កំណែទម្រង់នេះ គឺជាកំណែទម្រង់ស្នូលមួយក្នុងចំណោមកំណែទម្រង់ស្នូលទាំង៣របស់រាជរដ្ឋាភិបាលពោលគឺ៖ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ហើយកំណែទម្រង់តាមវិស័យនានា ក៏ត្រូវបន្សីជាមួយនឹងកំណែទម្រង់ទាំង៣នេះផងដែរ។

ដោយផ្អែកលើមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសុខសន្តិភាព និងស្ថេរភាពនយោបាយ បានផ្តល់នូវកាលានុវត្តភាពដល់រាជរដ្ឋាភិបាលក្នុងការកំណត់នូវចក្ខុវិស័យជាអាទិភាពសម្រាប់ការលើកកម្ពស់អភិបាលកិច្ចល្អនៃស្ថាប័នសាធារណៈគ្រប់លំដាប់ថ្នាក់តាមរយៈការពង្រឹង និងកែលំអជាប្រចាំ។ ផ្អែកតាមចក្ខុវិស័យនេះ ក្របខណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ ច្បាប់ កម្មវិធីជាតិ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្ត ដែលយើងបានចាប់ផ្តើមក្នុងដំណាក់កាលដំបូងជាប្រវត្តិសាស្ត្រសម្រាប់ការងារកំណែទម្រង់នៅរដ្ឋបាលថ្នាក់ឃុំ សង្កាត់ តាមរយៈការរៀបចំឱ្យមានការបោះឆ្នោតដោយផ្ទាល់ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសនាឆ្នាំ២០០២ និងការរៀបចំឱ្យមានប្រព័ន្ធ និង

នីតិវិធីការងារដែលផ្ដល់ស្វ័យភាពដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោត ដើម្បីប្រែក្លាយរដ្ឋបាលឃុំ សង្កាត់ឱ្យទៅជាស្ថាប័នអភិបាលកិច្ចស្ថិតក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជាប់ឆ្នោត ជារដ្ឋបាលមូលដ្ឋានតំណាងឱ្យសម្លេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជារដ្ឋបាលមូលដ្ឋានដែលមានប្រព័ន្ធគ្រប់គ្រងតាមបែបផែនអភិបាលកិច្ចល្អ និងមានលទ្ធភាពក្នុងការផ្ដល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីដោះស្រាយជាបឋមនូវបញ្ហាដែលកើតឡើងនៅតាមមូលដ្ឋានបានទាន់ពេលវេលា និងឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ផ្អែកលើលទ្ធផលជាវិជ្ជមាន មេរៀន និងបទពិសោធន៍នៃការធ្វើកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ កំណែទម្រង់នេះក៏ត្រូវបានបន្តអនុវត្តនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស តាមរយៈការរៀបចំឱ្យមានការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០០៩ និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និង នីតិវិធីការងារ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីជំរុញលើកកម្ពស់ និងធានាចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ដើម្បីធានាដល់ការសម្រេចបាននូវចក្ខុវិស័យដ៏ច្បាស់លាស់របស់រាជរដ្ឋាភិបាលក្នុងការ **បង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃការចូលរួមតាមលក្ខណៈប្រជាធិបតេយ្យ ដំណើរការប្រកបដោយតម្លាភាព និងគណនេយ្យភាពក្នុងការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងការផ្ដល់សេវាសាធារណៈឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ** រាជរដ្ឋាភិបាលបានកំណត់នូវរបៀបវារៈការងារមួយដែលមានរយៈពេល១០ឆ្នាំ (ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩) នោះគឺ**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**។

កម្មវិធីជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់កិច្ចដំណើរការកំណែទម្រង់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដ៏ទូលំទូលាយ និងស៊ីជម្រៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនគ្រាន់តែមានផលប៉ះពាល់មកលើរដ្ឋបាលថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ ប៉ុន្តែកំណែទម្រង់នេះក៏មានផលប៉ះពាល់មកលើស្ថាប័ននានានៅថ្នាក់ជាតិផងដែរ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** !

គិតមកទល់ពេលនេះ យើងបានអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអស់រយៈពេលជិត២ទសវត្សមកហើយ ហើយបើពិនិត្យមើលលើការអនុវត្តកម្មវិធីជាតិសម្រាប់

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ យើងបានអនុវត្តអស់រយៈពេលជាង៧ឆ្នាំហើយ មានន័យថា យើងបានបញ្ចប់ការអនុវត្តដំណាក់កាលទី១ និងដំណាក់កាលទី២ ដោយសម្រេចបានសមិទ្ធផលនានាជាច្រើនស្របតាមការរំពឹងទុក ដែលពេលនេះយើងកំពុងតែរៀបចំចាប់ផ្តើមអនុវត្តដំណាក់កាលទី៣ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ។ នាពេលបន្តិចទៀតនេះ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើសេចក្តីរាយការណ៍ជូនអង្គសន្និសីទជាតិអំពីវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅសំខាន់ៗនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមគូសបញ្ជាក់ជូននូវសមិទ្ធផលធំៗពីរដែលយើងសម្រេចបានឆ្លើយតបទៅនឹងចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវសហមជ្ឈការ នោះគឺ៖

**ទីមួយ៖** ផ្តោតលើការសម្របសម្រួល ឯកភាពស្រុះស្រួលគ្នាខាងនយោបាយ យើងបានរៀបចំធ្វើការបោះឆ្នោតដោយផ្ទាល់ និងមិនផ្ទាល់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដើម្បីបង្កើតឡើងនូវក្រុមប្រឹក្សាគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិយ៉ាងទៀងទាត់ទៅតាមអាណត្តិដែលកំណត់ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ។ ក្រុមប្រឹក្សាដែលជាប់ឆ្នោតទាំងនេះគឺជាស្ថាប័នអភិបាលតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការវិសហមជ្ឈការដ៏មានសក្តានុពល ជាតំណាងឱ្យផលប្រយោជន៍ដោយផ្ទាល់របស់សហគមន៍ និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។ ដើម្បីធានាឱ្យក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាលនីមួយៗសម្រេចបាននូវបេសកកម្មរបស់ខ្លួនក្នុងការបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ យើងបានរៀបចំឡើងវិញ និងដាក់ឱ្យដំណើរការនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងបំពេញតួនាទីក្នុងនាមជាតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន។ ប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សតាមបែបវិមជ្ឈការដែលផ្តល់សិទ្ធិអំណាច និងស្វ័យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអភិវឌ្ឍសមត្ថភាពបុគ្គលិកប្រកបដោយប្រសិទ្ធភាពកំពុងត្រូវបានរៀបចំអនុវត្ត និងកែលម្អជាបណ្តើរៗ។ ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយមានការចូលរួមពីប្រជាពលរដ្ឋក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដើម្បីធានាដល់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព និងសមធម៌។ មូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុកក៏ត្រូវបានរៀបចំបង្កើត និងបានផ្ទេរមូលនិធិទៅឱ្យរដ្ឋបាលទាំងនោះសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចប្រតិបត្តិការក្នុងការផ្តល់សេវា និងការអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋាននានាក្នុងក្របខ័ណ្ឌ

មុខងារជាអាណត្តិទូទៅរបស់ខ្លួន ហើយទំហំមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកក៏ត្រូវបានបង្កើនជារៀងរាល់ឆ្នាំអាស្រ័យដោយកំណើននៃថវិកាជាតិដែលបានមកពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ ជាមធ្យម៧%ប្រកបដោយចីរភាពរយៈពេលវែងជិត២ទសវត្សរ៍កន្លងទៅនេះ។ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធនៃរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិបានធ្វើឱ្យផ្លាស់ប្តូរនូវខ្សែគណនេយ្យភាព ដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវមានគណនេយ្យភាពជាចម្បងចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល អំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានា។

**ទីពីរ៖** យើងសម្រេចបាននូវការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការផ្ទេរមុខងារ និងធនធានក្នុងវិស័យអាទិភាពនានាជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងរយៈពេលកន្លងមកនេះ មានក្រសួង ស្ថាប័នចំនួន១៤ដែលស្ថិតនៅក្នុងវិស័យអាទិភាពបានចូលរួមក្នុងកិច្ចដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ មុខងារមួយចំនួនត្រូវបានផ្ទេរតាមរយៈការធ្វើប្រតិភូកម្ម និងមុខងារមួយចំនួនទៀតបានផ្ទេរតាមរយៈការប្រគល់តែម្តង។ តាមរយៈការផ្ទេរមុខងារដោយភ្ជាប់មកជាមួយនូវសិទ្ធិអំណាច និងធនធាន រួមមានទាំងធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្លាយជាស្ថាប័នដែលមានសមត្ថភាព និងមានលទ្ធភាពជាបណ្តើរៗក្នុងការទទួលខុសត្រូវលើការរៀបចំ គ្រប់គ្រង និងចាត់ចែងការផ្តល់សេវាសាធារណៈ និងការអនុវត្តគម្រោងអភិវឌ្ឍនានា ដើម្បីបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទៅតាមតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗ។

ឯកឧត្តម លោកជំទាវ លោក លោកស្រីពិតជាបានជ្រាបរួចហើយថា ការធ្វើវិមជ្ឈការ គឺជាដំណើរការនៃការផ្ទេរមុខងារ ធនធាន និងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍដែលពាក់ព័ន្ធនឹងតម្រូវការនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបតម្រូវការឱ្យកាន់តែឆាប់រហ័ស និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ។ តាមរយៈការធ្វើវិមជ្ឈការ យើងនឹងបង្ខិតរដ្ឋបាលឱ្យទៅនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋ តាមរយៈការផ្ទេរមុខងារ ធនធាន និងការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ដែលប្រការនេះបានជំរុញដល់ការលើកកម្ពស់ ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលកាន់តែជិតស្និទ្ធ និងកាន់តែមានការជឿជាក់។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ យើងត្រូវមានផែនការច្បាស់លាស់ មានការពិគ្រោះយោបល់ និងមានការប្រុងប្រយ័ត្ន ដោយផ្អែកលើស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជាយើងផង និងការរៀនសូត្រពីមេរៀន និងបទពិសោធន៍របស់បណ្តាប្រទេសនានាក្នុងតំបន់ និងក្រៅតំបន់ផង ដើម្បីធានាដល់ការគ្រប់គ្រង និងដោះស្រាយបាននូវហានភ័យនានាដែលអាចកើតមានឡើងជាយថាហេតុ។

ផ្អែកតាមស្ថានភាពជាក់ស្តែងនៃដំណាក់កាលនេះ ភាពជោគជ័យនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺអាស្រ័យទៅលើការប្តេជ្ញាចិត្តខាងនយោបាយរបស់ក្រសួង ស្ថាប័ននានាក្នុងការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលការណ៍នានាដែលបានកំណត់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិ។ ទន្ទឹមនឹងនេះ រដ្ឋបាលនីមួយៗនៃថ្នាក់ក្រោមជាតិក៏ត្រូវប្រឹងប្រែងពង្រឹងសមត្ថភាព ការទទួលខុសត្រូវក្នុងការអនុវត្តមុខងារដែលបានផ្ទេរឱ្យប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងភាពជឿទុកចិត្តបាន ដើម្បីទទួលបានការគាំទ្រពីប្រជាពលរដ្ឋ និងដើម្បីជំរុញលើកទឹកចិត្តដល់ក្រសួង ស្ថាប័ននានាក្នុងការផ្ទេរមុខងារ និងធនធានឱ្យបានកាន់តែច្រើនថែមទៀត។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** !

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរំលឹកឡើងវិញអំពីមូលហេតុសំខាន់ចំនួន៣ដែលរាជរដ្ឋាភិបាលសម្រេចចិត្តធ្វើវិមជ្ឈការគឺៈ

**ទីមួយៈ ការពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្សៈ** ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុក្សជាលើកដំបូងកាលឆ្នាំ២០០២ និងការធ្វើវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់គឺមិនត្រឹមតែជាការសម្រេចចិត្តក្នុងការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលប៉ុណ្ណោះទេ ប៉ុន្តែការបោះឆ្នោតនេះជាការប្តេជ្ញាចិត្តចខាងនយោបាយដ៏មុតមាំរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹង ពង្រីកលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីពង្រឹងសន្តិភាព ស្ថេរភាពនយោបាយសម្រាប់ជាកាលានុវត្តភាពក្នុងការកសាងជាតិឡើងវិញ បន្ទាប់ពីការអនុវត្ត ប្រកបដោយជោគជ័យនូវនយោបាយឈ្នះ-ឈ្នះដែលបាននាំមកនូវសន្តិភាព ការឯកភាពជាតិ និងការឯកភាពទឹកដីយ៉ាងពេញលេញ។ សមិទ្ធផលនយោបាយដែលសម្រេចបាននៅថ្នាក់ឃុំ សង្កាត់បានក្លាយជាបទពិសោធន៍សម្រាប់កម្ពុជាយើងក្នុងការរៀបចំប្រព័ន្ធបោះឆ្នោតដោយផ្ទាល់ និងមិនផ្ទាល់ដើម្បីបង្កើតឡើងនូវក្រុមប្រឹក្សា ដែលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យនៅគ្រប់ថ្នាក់ រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាទាំងនេះគឺជាតួអង្គដ៏សំខាន់ក្នុងការអនុវត្តប្រព័ន្ធការងារតាមបែបផែនប្រជាធិបតេយ្យ និងវិមជ្ឈការ ដើម្បីពង្រឹងសិទ្ធិអំណាចរបស់សហគមន៍មូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋជាមួយក្រុមប្រឹក្សា

របស់ខ្លួនក្នុងការគ្រប់គ្រង ចាត់ចែង មូលដ្ឋាននីមួយៗ ដែលក្នុងន័យនេះ ប្រជាពលរដ្ឋបានក្លាយជាតួអង្គដ៏សំខាន់ និងសកម្មក្នុងសហគមន៍ និងមានសមត្ថភាពក្នុងការបង្កើនគណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន។ ជាងនេះទៅទៀត ប្រជាពលរដ្ឋកាន់តែមានសមត្ថភាពគ្រប់គ្រងលើការរស់នៅរបស់ខ្លួន និងមានឥទ្ធិពលលើការធ្វើសេចក្តីសម្រេចចិត្តនានាដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ខ្លួន តាមរយៈការចូលរួមកំណត់អំពីតម្រូវការ និងការឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។ រាជរដ្ឋាភិបាលបានផ្តល់គុណតម្លៃទៅលើប្រព័ន្ធដ៏មានសក្តានុពលនេះ។ អាស្រ័យហេតុនេះ ទោះបីជាសភាពការនយោបាយនៅកម្ពុជារយៈពេលចុងក្រោយមានការវិវឌ្ឍ បត់បែន ប្រែប្រួល ប៉ុន្តែរាជរដ្ឋាភិបាលនៅតែតម្កល់ការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការពង្រឹងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការនៅថ្នាក់ក្រោមជាតិឱ្យកាន់តែសកម្ម និងមានប្រសិទ្ធភាពថែមទៀត ដើម្បីឆ្លើយតបតម្រូវរបស់ប្រជាពលរដ្ឋ។

**ទីពីរ៖ ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន៖** ការធ្វើវិមជ្ឈការនឹងផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតប្រជាពលរដ្ឋផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការ និងសំណូមពរចាំបាច់នានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ទីបី៖ ការកៀរគរធនធាន៖** ការធ្វើវិមជ្ឈការនឹងបង្កើននូវប្រភពធនធាននានាក្នុងសហគមន៍ ដូចជាការប្រមូលផ្តុំនូវគំនិតផ្តួចផ្តើមដ៏សម្បូរណ៍បែបរបស់មូលដ្ឋាន ការកៀរគរកម្លាំងពលកម្មរបស់សហគមន៍ ការចូលរួម និងការផ្តល់មូលនិធិ។ ធនធាននានាត្រូវបានវិភាជន៍កាន់តែប្រសើរស្របតាមល័ក្ខខ័ណ្ឌជាក់ស្តែងរបស់មូលដ្ឋាន ហើយជាលទ្ធផលនឹងបង្កើនប្រសិទ្ធភាព និងគុណតម្លៃថវិកាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ផ្អែកលើសមិទ្ធផលធំៗដែលសម្រេចបាននាពេលកន្លងមកនេះ បានបង្ហាញឱ្យឃើញថាការកំណត់នូវចក្ខុវិស័យដ៏ច្បាស់លាស់ និងការខិតខំប្រឹងប្រែងអនុវត្តប្រកបដោយឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលចំពោះកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុតក្នុងរយៈពេលជិត២ទសវត្សរ៍កន្លងមកនេះ ក្នុងការធ្វើឱ្យប្រសើរឡើងជាលំដាប់នូវការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការចូលរួមកាត់បន្ថយភាពក្រីក្រប្រកបដោយសមធម៌។

ទន្ទឹមនឹងសមិទ្ធផលធំៗដូចបានគូសបញ្ជាក់ខាងលើ យើងក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវរួមគ្នាពិនិត្យ និងដោះស្រាយ មានជាអាទិ៍៖

**ទីមួយ ៖ ការពុំទាន់ស្រុះស្រួលមូលគំនិតគ្នាអំពីការអនុវត្តគោលនយោបាយវិមជ្ឈការ** ជាពិសេសក្នុងក្របខ័ណ្ឌនៃការស្វ័យភាព និងការទទួលខុសត្រូវក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអនុវត្តកំណែទម្រង់វិមជ្ឈការតម្រូវឱ្យមានការតាំងចិត្តខាងនយោបាយរយៈពេលវែង និងមានការចូលរួមពីក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលទាំងមូល ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែងកន្លងមក ក្រសួង ស្ថាប័នមួយចំនួននៅមានភាពស្ទាក់ស្ទើរ រារែក អល់អែកក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ។ ព្រមជាមួយគ្នានេះ ទោះបីក្រសួង ស្ថាប័នមួយចំនួនបន្តការតាំងចិត្តខាងនយោបាយក្នុងការអនុវត្តគោលនយោបាយនេះក៏ដោយ ក៏ល្បឿន និងបែបផែននៃការអនុវត្តកិច្ចការនេះមានភាពខុសៗគ្នាផងដែរ។ អាស្រ័យហេតុនេះ សម្រាប់រយៈពេលបន្តទៀត ចាំបាច់ត្រូវមានការសម្របសម្រួលដោះស្រាយក្នុងកម្រិតនយោបាយដើម្បីស្វែងរកការឯកភាពគ្នាឡើងវិញ សំដៅបន្តអនុវត្តការប្ដេជ្ញាចិត្តខាងនយោបាយរបស់រាជរដ្ឋាភិបាលក្នុងដំណើរការកំណែ
ទម្រង់ដែលកំពុងឈានដល់ដំណាក់កាលកាន់តែស៊ីជម្រៅ និងសាំញ៉ាំនេះ។

**ទីពីរ ៖ ការអនុវត្តគោលនយោបាយ កម្មវិធី និងលិខិតបទដ្ឋាននានានៅពុំទាន់បានផ្ដោតទៅលើមូលដ្ឋានឱ្យបានស៊ីជម្រៅ** ជាក់ស្ដែង ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១ និងដំណាក់កាលទី២កន្លងមក ពុំទាន់បានផ្ដោតការយកចិត្តទុកដាក់ឱ្យបានស៊ីជម្រៅក្នុងការប្រែក្លាយគោលនយោបាយ កម្មវិធី និងលិខិតបទដ្ឋាននានាឱ្យទៅជាការអនុវត្តជាក់ស្ដែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង និងជាអាទិភាពរបស់មូលដ្ឋាននៅឡើយ ពិសេស ការឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី កុមារ ជនក្រីក្រ ជនពិការ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងៗទៀត។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ចាំបាច់ត្រូវរៀបចំជាកម្មវិធី និងគម្រោងនានាដោយផ្ដោតទៅលើការដោះស្រាយបញ្ហាជាក់លាក់ ឬការជំរុញឱ្យមានការផ្លាស់ប្ដូរឥរិយាបថតាមបែបផែនដ៏ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពបំផុតរបស់មូលដ្ឋានប្រកបដោយបរិយាប័ន្ន។

**ទីបី ៖ ការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជន៖** កន្លងមក ការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជនមានវឌ្ឍនភាពជាច្រើន តាមរយៈការចូលរួមក្នុងកិច្ចដំណើរការរៀបចំតាក់តែងគោលនយោបាយ ការកសាងផែនការ ការអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាព និងជាពិសេសការអនុវត្តការងារគណនេយ្យភាពសង្គម។ ក៏ប៉ុន្តែការចូលរួមទាំងនេះនៅពុំទាន់ពេញលេញ និងមាននិរន្តរភាពនៅឡើយ។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវបន្តលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ព្រមទាំងរួម

ចំណែកលើកកម្ពស់អភិបាលកិច្ចល្អ ការអភិវឌ្ឍសមត្ថភាព និងលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមទៀត។

ក្រៅពីនេះ យើងក៏នៅជួបប្រទះបញ្ហាប្រឈមជាច្រើនទៀត ដោយសារតែកំណែទម្រង់នេះបានឈានចូលក្នុងដំណាក់កាលផ្ទេរមុខងារ និងធនធាន ជាដំណើរការដ៏ស្មុគស្មាញ និងសាំញ៉ាំ ដោយសារដំណើរការនេះមានផលប៉ះពាល់ដល់រចនាសម្ព័ន្ធ ប្រព័ន្ធ សិទ្ធិអំណាចនៃក្រសួងស្ថាប័ននានា។ ព្រមជាមួយគ្នានេះ បញ្ហាប្រឈមដែលត្រូវការពេលវេលា និងការប្តេជ្ញាចិត្តដ៏មោះមុត គឺការធ្វើឱ្យមានការផ្លាស់ប្តូរនូវផ្នត់គំនិត និងរបៀបរបបបំពេញការងាររបស់មន្ត្រីទៅតាមបែបបទថ្មីនៃកំណែទម្រង់។

ទោះបីយ៉ាងណាក៏ដោយ ក៏យើងទាំងអស់គ្នាត្រូវយល់ថា ការធ្វើវិមជ្ឈការ គឺជាមាគ៌ា ឬជាជម្រើសដ៏សមស្រប និងមានប្រសិទ្ធភាពបំផុតនៃប្រព័ន្ធគ្រប់គ្រងកិច្ចការសាធារណៈ ដែលប្រទេសជាច្រើនលើសកលលោកកំពុងប្រកាន់យក។

ហេតុនេះ បើទោះជាមានបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើក៏ដោយ ក៏យើងមានកាលានុវត្តភាព ជាច្រើនសម្រាប់ភាពជោគជ័យនៃការអនុវត្តកម្មវិធីជាតិក្នុងដំណាក់កាលទី៣ ដែលក្នុងឱកាសនេះ ខ្ញុំសូមគូសបញ្ជាក់អំពីកាលានុវត្តភាពសំខាន់ៗជាអាទិ៍៖

**ទីមួយ**៖ រចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីបំពេញការងារ ព្រមទាំងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួចរាល់ និងត្រូវបានពង្រឹងជាបន្តបន្ទាប់ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានផ្តល់សិទ្ធិអំណាចជាបណ្តើរៗក្នុងការដោះស្រាយបញ្ហា និងតម្រូវការអភិវឌ្ឍនៅតាមមូលដ្ឋាន ដែលជាមូលដ្ឋានដ៏សំខាន់ដើម្បីប្រែក្លាយសិទ្ធិអំណាចទាំងនេះឱ្យទៅជាលទ្ធផលជាក់ស្តែងក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានកាន់តែទូលំទូលាយប្រកបដោយភាពជឿជាក់ថែមទៀត។

**ទីពីរ** ៖តាមរយៈការអនុវត្តកម្មវិធីជាតិក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២កន្លងមកភាគីពាក់ព័ន្ធនានាមានការយល់ដឹងកាន់តែច្បាស់អំពីចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ ដែលតាមរយៈនេះ យើងនឹងពង្រឹងថែមទៀតនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងការពុះពារជម្នះដោះស្រាយបញ្ហាប្រឈមនានា ដើម្បីជំរុញដំណើរការកំណែទម្រង់ឱ្យបោះជំហានទៅមុខកាន់តែរឹងមាំថែមទៀត។

**ទីបី** ៖ កម្មវិធីកំណែទម្រង់ទាំង៣ រួមមាន កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកំណែទម្រង់តាមវិស័យនានាបាន និងកំពុងសហការគ្នាកាន់តែជិតស្និទ្ធ និងធ្វើសុខដុមនីយកម្មនូវផែនការសកម្មភាពនៃកម្មវិធីកំណែទម្រង់ទាំងនេះ។

**ទីបួន** ៖ ប្រព័ន្ធព័ត៌មានសង្គម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានាដែលធ្វើឱ្យមានការកើន

ឡើងនូវការប្រាស្រ័យទាក់ទងគ្នារបស់សាធារណជន គឺជាកាលានុវត្តភាពដ៏ធំធេងមួយ ក្នុងការផ្តល់ព័ត៌មានផ្សេងៗតាមគ្រប់រូបភាព ដើម្បីជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការកំណែទម្រង់កាន់តែទូលំទូលាយថែមទៀត។

អាស្រ័យហេតុនេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាម គ.ជ.អ.ប ខ្ញុំសូមជំរុញលើកទឹកចិត្តក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវប្រើប្រាស់កាលានុវត្តភាពទាំងនេះរួមគ្នាដោះស្រាយបញ្ហាប្រឈមនានា ដើម្បីបង្កើនតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងបន្តអនុវត្តកម្មវិធី និងគម្រោងនានា ដើម្បីបង្ហាញឱ្យឃើញពីផលប្រយោជន៍ជាក់ស្តែងជូនប្រជាពលរដ្ឋ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី** !

ផ្អែកលើសមិទ្ធផលដែលបានកសាង បញ្ហាប្រឈមដែលធ្លាប់ជួបប្រទះ មេរៀន និងបទពិសោធន៍ដែលប្រមូលបាននាពេលកន្លងមក យើងអាចនឹងពិនិត្យកែលម្អនូវចក្ខុវិស័យ និងគោលដៅនានានៃកម្មវិធីជាតិរយៈពេល១០ឆ្នាំឱ្យបានច្បាស់លាស់ជាងមុន ជាពិសេសពាក់ព័ន្ធនឹងការបែងចែកឱ្យបានច្បាស់លាស់អំពីប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទៅតាមប្រភេទដែលមានចរិតលក្ខណៈ និងមានតួនាទីជារដ្ឋបាលកម្រិតតំបន់ និងរដ្ឋបាលថ្នាក់មូលដ្ឋាន ព្រមទាំងប្រព័ន្ធរដ្ឋបាលសម្រាប់គ្រប់គ្រងទីក្រុង ទីប្រជុំជន និងជនបទ។ ការបែងចែកតាមចរិតលក្ខណៈបែបនេះនឹងធ្វើឱ្យមានភាពងាយស្រួលក្នុងការបែងចែកឡើងវិញនូវតួនាទី និងការទទួលខុសត្រូវរវាងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះឱ្យកាន់តែមានភាពច្បាស់លាស់ ក៏ដូចជាមានភាពងាយស្រួលក្នុងការផ្ទេរមុខងារ និងធនធានស្របតាមចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះផងដែរ។

ផ្អែកលើទស្សនវិស័យនេះ យើងនៅតែបន្តផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍរដ្ឋបាលក្រុង ស្រុកឱ្យក្លាយទៅជារដ្ឋបាលមូលដ្ឋានយ៉ាងពិតប្រាកដ ដែលជាស្ថាប័នប្រជាធិបតេយ្យ ជាស្ថាប័នតំណាងប្រជាពលរដ្ឋ ជាស្ថាប័នមានស្វ័យភាព មានគំនិតផ្តួចផ្តើមក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីរួមគ្នាជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ក្នុងន័យនេះ យើងនឹងបន្តជំរុញការអភិវឌ្ឍស្ថាប័ននៃរដ្ឋបាលក្រុង ស្រុក ដោយផ្តោតលើការផ្ទេរមុខងារតាមវិស័យអាទិភាពនានា បន្តពង្រឹងប្រព័ន្ធអភិបាលកិច្ច កែលម្អ វិធីសាស្ត្រអភិវឌ្ឍសមត្ថភាព និងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធរបស់រដ្ឋបាលនេះជារដ្ឋបាលឯកភាព ដើម្បីធានាដល់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារផ្តល់សេវាតាមវិស័យនានាជូនប្រជា

ពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពបន្ថែមទៀត។

អាស្រ័យហេតុនេះ ការរៀបចំឡើងនូវសន្និសីទជាតិនាពេលនេះ គឺជាឱកាសដ៏ល្អបំផុតសម្រាប់ឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនានាដែលយើងខិតខំរួមគ្នាសម្រេចបាន និងមេរៀនបទពិសោធន៍នានាដែលយើងបានជួបប្រទះ និងបានចងក្រងសម្រាប់ធ្វើជាមូលដ្ឋាននៃការពង្រឹង ពង្រីក និងកែលម្អការអនុវត្តនាពេលអនាគត ព្រមទាំងការលើកឡើងអំពីបញ្ហាប្រឈមនានាដែលយើងត្រូវរួមគ្នាពិនិត្យ និងដោះស្រាយ។ ដូច្នេះ ខ្ញុំសង្ឃឹមថា អង្គសន្និសីទជាតិរបស់យើងនឹងប្រើប្រាស់ពេលវេលាដ៏មានតម្លៃក្នុងរយៈពីរថ្ងៃនេះ ដើម្បីចែករំលែកមេរៀន បទពិសោធន៍ និងចូលរួមពិភាក្សា និងស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមនានាឱ្យបានសកម្ម និងផុលផុសដើម្បីឈានទៅសម្រេចបាននូវគោលបំណងនៃសន្និសីទជាតិរបស់យើង។

ផ្អែកលើរបាយការណ៍ បទអន្តរាគមន៍ និងលទ្ធផលនៃការជជែកពិភាក្សាគ្នាក្នុងអង្គសន្និសីទជាតិនេះ យើងនឹងធ្វើសេចក្តីរាយការណ៍ និងគោរពស្នើសុំអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ក្នុងពិធីបិទសន្និសីទជាតិនារសៀលថ្ងៃស្អែក។

មុននឹងបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់បន្តចូលរួម និងគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងរួមរបស់យើង គឺការពង្រឹងគុណភាពសេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព និងសមធម៌។

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរដល់អង្គសន្និសីទជាតិរបស់យើងបានដំណើរការទៅប្រកបដោយលទ្ធផលជាផ្លែផ្កា និងសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកសន្និសីទជាតិចាប់ពីពេលនេះតទៅ។

**សូមអរគុណ។**